# គំនុំអតីត

## (An Old Diary)



រថយន្តកស្ទូពណ៌ក្រហម បានបរចូលទៅក្នុងបរិវេណភូមិគ្រឹះដ៏ស្កុកស្កម្ភមួយនាសង្កាត់ភ្នំពេញថ្មី។ នៅពីមុខតួគេហដ្ឋានដ៏ទំនើបធំចង្រ្កឹង មានវាលស្មៅនិងសួនឱទ្យានដ៏ស្រស់ប្រណីត លម្អដោយកូនស្រះប្រកបដោយផ្កាសេតុប្បល (ព្រលិតស) និងផ្កាលំចង់រីករហង់លាយចម្រុះគ្នា នៅជុំវិញឧបករណ៍បាញ់ទឹកដែលរចនាចេញជារូបផ្កាឧប្បលពណ៌មាស ព្រួសសរសៃរទឹកប្រាំខ្សែឡើងទៅលើអាកាស។ សុភក្រ្តាបញ្ជាយានឱ្យលូនលឿនស្ទៅលើផ្លូវនៅចន្លោះសួនផ្កា ឆ្ពោះទៅទីចំណតរថយន្តដែលស្ថិតនៅចំហៀងខាងស្តាំនៃផ្ទះ។ បន្ទាប់មកនារីក៏យាត្រាចរចូលទៅក្នុងគេហដ្ឋាន ឆ្លងកាត់តាមបន្ទប់ទទួលភ្ញៀវដែលបង្ហាញដោយឥតលាក់លៀមនូវភាពថ្កុំថ្កើងរបស់ម្ចាស់ផ្ទះ ... កម្រាលព្រំនិងគ្រឿងសង្ហារឹមសុទ្ធតែធុនថ្លៃ នាំចូលមកពីបរទេស។ នៅចន្លោះទូរ Cabinet ដ៏ប្រណីតពីរដែលដាក់តាំងវត្ថុសិល្បៈល្អៗច្នៃចេញពីកែវចរណៃចែងចាំងពន្លឺព្រោងព្រាយ មានរូបចម្លាក់តោញីឈ្មោលមួយគូ រចនាចេញពីថ្មកែវពណ៌ស មានកែវភ្នែកជាគុជធម្មជាតិពណ៌ខ្មៅទាំងគ្រាប់ សំញែងឫទ្ធិគំនាប់មនុស្សទាំងពួងដែលបានចូលមកដល់។

នាងកញ្ញាដើរលេះរលាំងបម្រុងនឹងឡើងជណ្តើរទៅលើ ស្រាប់តែមានសំលេងមួយស្រែកហៅនាងពីក្រោយ "សុភក្រ្តា! ហេតុអីថ្ងៃនេះ កូនឆាប់ត្រលប់មកផ្ទះ?"

នារីក្មេងបែរប្រាណទៅរកម្ចាស់សំលេង ដែលជាស្ត្រីមួយរូបមានវ័យប្រមាណជាងពាក់កណ្តាលមនុស្ស ភ័ក្ត្រស្រស់ស្រទន់ស្លូតបូត តែនៅពេលគាត់បានឃើញមុខនាងក្រមុំពេលណា ក្តីបារម្ភបានលេចឡើងយ៉ាងច្បាស់លើផ្ទៃមុខស្ត្រីចំណាស់ គាត់សួរយ៉ាងរហ័ស "ពុទ្ធោកូន ... នេះកូនមានរឿងអី ... ម៉េចក៏ ... ទឹកមុខអាក្រក់ម្ល៉េះ..."

សុភក្រ្តាខំប្រឹងញញឹម ដើម្បីលួងចិត្តម្តាយកុំឱ្យបារម្ភ "អត់មានរឿងអីទេ ម៉ាក់"

ស្ត្រីចំណាស់ខិតចូលជិតនាងក្រមុំ មុខកាន់តែសម្តែងក្តីព្រួយ "កូនទៅយកអាវនរណាមកពាក់ បានជាធំរលុងយ៉ាងនេះ?"

សុភក្រ្តខំបន្តស្នាមញញឹមទាំងលំបាក ខំនិយាយបែបរួសរាយ "មិត្តរបស់កូនម្នាក់ មានគ្រោះថ្នាក់ចរាចរណ៍ ... កូនបានជួយជូនទៅមន្ទីរពេទ្យ ... គេមានសុវត្ថិភាពហើយ ... តែអាវកូនប្រលាក់ឈាមខ្ទះៗ ទើបស្វាមីគេឱ្យអាវនេះមកកូនដើម្បីពាក់ពីក្រៅ ... សុំទោសអ្នកម៉ាក់ ... កូនទើបនឹងចេញមកពីពេទ្យ កូនសុំទៅងូតទឹកសិនហើយ!" ពោលស្ទើរមិនទាន់ផុតមាត់ នាងកញ្ញាស្ទុះរត់ឡើងជណ្តើរ គេចចេញពីម្តាយភ្លាម ព្រោះខ្លាចគាត់សួរនាំច្រើនទៀត។

អ្នកស្រីសុមន្ទារតាមសម្លឹងមើលកូនដោយកែវភ្នែកព្រួយបារម្ភ គាត់ជឿពាក្យនាងក្រមុំតែហាសិបភាគរយប៉ុណ្ណោះ ក្នុងចិត្តគាត់ដឹងច្បាស់ថាមានរឿងលើសពីអ្វីដែលគាត់បានឮ តែគាត់ទប់ចិត្តមិនឡើងជណ្តើរទៅតាមដេញដោលដំរិតសួរការណ៍នាងភ្លាមទេ ព្រោះសុភក្រ្តាជាមនុស្សមានះ ឬបើហៅតាមបែបមិនសូវពិរោះគឺ **ក្បាលរឹង** តាំងពីតូច ចូលចិត្តដោះស្រាយបញ្ហាអ្វីៗដោយខ្លួនឯង បើនាងមិនព្រមធ្វើអ្វីមួយហើយ ទោះជាបង្ខំយ៉ាងណាក៏ឥតប្រយោជន៍ តែបើនាងចង់ធ្វើអ្វីមួយវិញ ទោះជាឃាត់យ៉ាងណាក៏មិនជាប់ដែរ ... កាន់តែបង្ខំណាស់ លទ្ធផលមុខតែរឹតតែផ្ទុយបញ្ច្រាសមិនខាន។ ម្យ៉ាងទៀត សុភក្រ្តាជាមនុស្សខ្លើមមន្ទីរពេទ្យបំផុត ឱ្យតែបានចូលហើយ ពេលចេញមកវិញ ត្រូវរត់រកកន្លែងងូតទឹកឱ្យបានឆាប់បំផុត។

ចូលដល់ក្នុងបន្ទប់ដំណេកនាងកាលណា សុភក្រ្តាប្រញាប់ដោះសម្លៀកបំពាក់ដើម្បីជម្រះកាយ។ ពេលឃើញស្នាមឈាមប្រលាក់លើអាវ នាងលាន់មាត់ "សំណាងហើយ ដែលអ្នកម៉ាក់មិនបានឃើញអាវប្រលាក់ឈាមនេះ កុំអីគាត់ច្បាស់ជាគាំងបេះដូងមិនខាន!"

ដំបូងនាងបម្រុងបោះអាវទៅក្នុងកន្ត្រកដាក់សម្លៀកបំពាក់ប្រលាក់ ដើម្បីទុកឱ្យអ្នកបម្រើយកទៅបោកសម្អាត ស្រាប់តែនាងទាញអាវយកមកកាន់ពិនិត្យផ្ទៀងផ្ទាត់លើដៃវិញ ... នាងដកដង្ហើមធំ ធ្វើមុខស្រពោន ... អាវនេះមានប្រលាក់ឈាមរបស់អ្នកដែល



នាងគិតទាំងយប់ទាំងថ្ងៃ ... វាបានប៉ះពាល់យ៉ាងជិតស្និទ្ធនឹងរាងកាយរបស់គេ បានទាំងរងនូវទឹកភ្នែករបស់នាងរាប់រយតំណក់ ដែលស្រក់យ៉ាងខ្លោចផ្សាចំពោះគេទៀតផង... តើគួរលាងសម្អាត បំភ្លេចស្លាកស្នាមទាំងអស់នេះចោល ហើយចាត់ទុកថាគ្មានរឿងអ្វីបានកើតឡើង? មាណវីសម្លឹងអាវកំសត់អស់មួយស្របក់ ក៏សម្រេចចិត្តបត់អាវនោះយ៉ាងស្អាត ដាក់វាទៅក្នុងថង់ប្លាស្ទិកមួយ ហើយលាក់ទៅបាតថតទូរសម្លៀកបំពាក់របស់នាង។

រួចរាល់ហើយ នារីប្រញាប់ចូលទៅជម្រះកាយក្នុងបន្ទប់ទឹក។

... សុភគ្រ្តាបានផ្លាស់សម្លៀកបំពាក់និងសិតសក់រួចហើយ តែនាងនៅអង្គុយសំកុក នៅទល់មុខកញ្ចក់សម្អាង សម្លឹងភ្លឹះៗទៅលើវង់ភ័ក្ត្រនៃនារីម្នាក់ដែលកំពុងតែសម្លឹង ភ្លឹះៗមើលមកនាងវិញដោយកែវភ្នែកក្រៀមក្រំ ជន់ដោរដោយទុក្ខព្រួយ ... បបូរមាត់នាងកម្រើកឡើង វាចាខ្សឹបៗក៏លាន់ចេញមក "ដួង សម្បត្តិសុភគ្រ្តា ... នេះគឺជារូបឯងមែនទេ? ហេតុអីពីមួយថ្ងៃទៅមួយថ្ងៃ ឯងកាន់តែក្លាយទៅជាមនុស្សផ្សេង ដែលយើងមិនធ្លាប់ស្គាល់? តើភាពរឹងមាំក្លាហានរបស់ឯងបាត់ទៅណាអស់ហើយ? ហេតុអីក៏ទៅជាបែបនេះ? ហេតុអី? ហេតុអី?..." មានតែសំណួរ គ្មានចម្លើយ។



នារីដើរទៅបើកថតតុក្បាលដំណេក យកសៀវភៅកំណត់ហេតុចាស់មួយចេញមក នាងផ្តួលខ្លួនទៅលើគ្រែ លើកដៃអង្អែលក្របសៀវភៅថ្នមៗ ទឹកនេត្រាហូរមករឹមៗ "លោកតា ... លោកតា ... ពួកយើងគួរតែសប្បាយចិត្តមែនទេ? ក្រុមហ៊ុនរតនៈសម្បត្តិទាំងមូលបានធ្លាក់មកក្នុងកណ្តាប់ដៃគ្រួសារយើងហើយ ហើយមនុស្សក្នុងត្រកូលកែវ រតនៈតែម្នាក់គត់ដែលមានសមត្ថភាពអាចប្រឆាំងនឹងយើងបាន ក៏ជិតលែងមានជីវិតលើលោកនេះដែរ ... គ្រប់យ៉ាងសមតាមបំណងរបស់យើងហើយ ... ប៉ុន្តែហេតុអីតាំងពីគម្រោងសងសឹករបស់ចៅបានសម្រេច សេចក្តីសុខរបស់ចៅក៏បាត់បង់បន្តិចម្តងៗទៅតាមនោះដែរ?" នារីលើកសៀវភៅទៅឱបដាក់លើទ្រូង "ហេតុអីពេលនេះចៅទទួលអារម្មណ៍ឈឺចាប់ខ្លាំងម្ល៉េះ? ហេតុអីជីវិតចៅប្រែជាទទេស្អាត លែងមានអ្វីជាទីសង្ឃឹមទៀត? លោកតា សូមលោកតាប្រាប់ចៅផង តើចៅត្រូវរស់នៅរបៀបណាទើបល្អ ... តើចៅត្រូវធ្វើយ៉ាងណាទើបចិត្តចៅឈប់ឈឺ ... តើធ្វើយ៉ាងណាទើបចៅអាចបំភ្លេចគេបាន?!..."

ក្នុងខណៈនោះ រូបភាពបុរសចំណាស់ម្នាក់រាងស្គមស្តើង មុខរាងជ្រុងបន្តិច បានផុសឡើងក្នុងមនោរម្មណ៍នាងក្រមុំ ... សុភគ្រ្តាបានវិលត្រលប់ទៅជាកុមារីអាយុដប់បីឆ្នាំវិញ ... នាងរត់ទៅបន្ទប់សិក្សាប្រចាំគ្រួសារ ដៃម្ខាងគ្រវីវត្ថុអ្វីម្យ៉ាង "លោកតា! លោកតាមើលនេះនែ៎ ពានរង្វាន់សិស្សពូកែគណិតសាស្ត្រប្រចាំប្រទេស!"

លោកតាបិទសៀវភៅនៅលើតុ ទាញទម្លាក់វ៉ែនតាឱ្យមកទើរលើចុងច្រមុះ ព្រោះគាត់ងើបមុខសម្លឹងមកសុភគ្រ្តាដោយប្រើកែវភ្នែកទទេ គាត់ត្រូវការជំនួយពីវ៉ែនតាតែក្នុងពេលអានឬសរសេរប៉ុណ្ណោះ។ លោកតាបញ្ចេញស្នាមញញឹមដោយសេចក្តីស្រលាញ់និងមោទនៈ សុភគ្រ្តារត់ទៅឱបលោកតាពីខាងក្រោយកៅអីដែលលោកកំពុងអង្គុយ នាងលើកពានរង្វាន់ទៅដាក់ពីមុខជីតា លោកតាក៏ចាប់យកទៅពិនិត្យមើល "តាអាចទាយដឹងតាំងពីដំបូងម្ល៉េះ ថាពានរង្វាន់នេះជារបស់អាត្រា!"

សុភគ្រ្តាឱបកជីតា ផ្អឹបថ្ពាល់នាងទៅលើកេសាបុរសចំណាស់ "លោកតាចាំមើលចុះ ទៅអនាគត អាត្រានឹងយកពានរង្វាន់ពាណិជ្ជករពូកែមកជូនលោកតាមិនខាន!"

ជីតាអង្អែលដៃចៅស្រី "តាជឿ ថាអាត្រាមុខតែធ្វើបាន!"

សុភគ្រ្តាឱនថើបថ្ពាល់ខាងឆ្វេងរបស់ជីតា ... នាងក៏បានវាសភ្នែកទៅលើសៀវភៅនៅលើតុ "សៀវភៅអីហ្នឹង លោកតា?"

"សៀវភៅកំណត់ហេតុ ..."

"សៀវភៅកំណត់ហេតុ? លោកតាសរសេរកំណត់ហេតុរាល់ថ្ងៃមែនទេ? ឱ្យអាត្រា សុំមើលផង លោកតា?"

លោកតាគ្រវីក្បាល "ឥឡូវនេះ មើលមិនទាន់បានទេ!"

"ម៉េចអញ្ចឹង លោកតា? លោកតាមានសរសេរពីអាត្រាទេ?"

រំពេចនោះ លោកស្រីសុមន្ទាបានដើរចូលមកក្នុងបន្ទប់ គាត់ញញឹមពេលឃើញ ជីតានិងចៅមួយគូនេះកំពុងស្និទ្ធស្នាលគ្នាបេះមិនដាច់ "លោកប៉ា អញ្ជើញទៅពិសាបាយ ... សុភក្ត្រាទៅផ្លាស់សំពត់អាវទៅកូន នឹងអាលទៅញុំាបាយ"

លោកតាដាក់ពានរង្វាន់ដែលកាន់នៅក្នុងដៃម្ខាងទៅលើតុ គាត់ចាប់យកសៀវភៅកំណត់ហេតុទុកដាក់ក្នុងថតតុរៀបរយហើយ ទើបគាត់ក្រោកឈរឡើង។ សុភក្ត្រាយកដៃម្ខាងឱបចង្កេះជីតា បណ្តើរគ្នាចេញពីបន្ទប់សិក្សា។

សម្រាប់សុភក្ត្រា លោកតាគឺជីតាផងនិងជាតំណាងឪពុកផង ព្រោះឪពុកនាងបានរងគ្រោះថ្នាក់ចរាចរណ៍ស្លាប់ចោលនាងទៅ តាំងពីនាងអាយុប្រាំបីឆ្នាំ។ ទោះជាកាលឪពុកនាងនៅមានជីវិត ក៏សុភក្ត្រាស្រលាញ់និងគោរពលោកតាយ៉ាងលើសលប់ គឺជីតា និងចៅស្រីមួយគូនេះប្រៀបបានទឹកនិងត្រី មានគំនិតនិងចរិតលក្ខណៈ ប្រហាក់ប្រហែលគ្នាខ្លាំងណាស់។ លោកតាជាពាណិជ្ជករ សុភក្ត្រាក៏មានចំណូលចិត្តលើមុខរបរនេះដែរ។ លោកតាបានបង្រៀនចៅស្រីឱ្យចេះរាប់លុយនិងចេះគិត លេខតាំងពីនាងមិន ទាន់ដល់អាយុចូលរៀននៅសាលាផង។ ឃើញនាងជាក្មេងឈ្លាសវៃនិងមានទេពកោសល្យខាងលេខនពន្តបែបនេះ លោកតា តែងដកដង្ហើមធំព្រោះបើប្រៀបទៅនឹងមុនីឧត្តមជាបងប្រុសនាង សុភក្ត្រាមានគុណសម្បត្តិសក្តិសមជាអ្នកទទួលស្នងបន្តវេន មុខរបរគ្រួសារជាងមុនីឧត្តមឆ្ងាយស្ទើរហៅមិនឮ។ មុនីឧត្តមចូលចិត្តតែខាងគូសវាស និងចង់ក្លាយខ្លួនជាស្ថាបត្យករតាំងពីកុមារ ប៉ុន្តែជាអកុសល គេជាកូនប្រុសទោលនិងជាកូនច្បងផង ដូច្នេះគេមានកតព្វកិច្ចជាអនាគតប្រមុខក្រុមហ៊ុនប្រចាំគ្រួសារ ទើបគេ ត្រូវបង្ខំចិត្តរៀនយកជំនាញខាងសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ទាំងដូចគេអូសបង្ស៊ីបញ្ច្រាសចុង។

លោកតាតែងពោលថា បើសុភក្ត្រាកើតមកជាកូនប្រុសមិនដឹងជាប្រសើរយ៉ាងណាទេ តែជីតាក៏តែងលួងលោមជីតាថាកុំឱ្យលោក អស់សង្ឃឹម នាងបានសន្យាថានឹងខំរៀនធ្វើជាពាណិជ្ជករស្រីដ៏ល្បី មិនឱ្យជីតាខកបំណងឡើយ។ តែអនិច្ចា សុបិនសុភក្ត្រា មិនទាន់ក្លាយជាការពិតផង ជីតាជាទីស្រលាញ់របស់នាងក៏បានចែកស្ថានទៅ ពេលនាងទើបចូលដល់វ័យ១៦ឆ្នាំប៉ុណ្ណោះ។ ក្នុងចំណោមវត្ថុសំណព្វចិត្តដែលលោកតាបានបន្សល់ទុកឱ្យនាង គឺសៀវភៅកំណត់ហេតុដែលនាងបានឃើញតែម្តងគត់ក្នុង ថ្ងៃនាងទទួលពានរង្វាន់ជ័យលាភីជាសិស្សឆ្នើមផ្នែកគណិតវិទ្យាប្រចាំប្រទេសនោះឯង។



កំណត់ហេតុត្រូវបានសរសេរដោយដៃលោកតាកុសលផ្ទាល់ រៀបរាប់អំពី ប្រវត្តិគ្រួសារនិងការធ្វើជំនួញរបស់ក្រុមហ៊ុន**សម្បត្តិពាណិជ្ជ**។ ប៉ុន្តែរឿងរ៉ាវ ដែលធ្វើឱ្យសុភក្ត្រាភ្ញាក់ផ្អើលនិងក្តោបយកការយកចិត្តទុកដាក់របស់នាង ទាំងស្រុង គឺប្រវត្តិជូរចត់របស់លោកតាទួត **ដួង សម្បត្តិ** ដែលកើតឡើង តាំងពីជាង៧០ឆ្នាំមុន។

កាលនោះលោកតាទួត ដួង សម្បត្តិជាកំលោះមួយរូប កំពុងត្រៀមខ្លួនទៅ បន្តការសិក្សានៅប្រទេសបារាំង ប៉ុន្តែជាអកុសល សង្គ្រាមលោកលើកទីពីរ បានផ្ទុះឡើងយ៉ាងសន្ធោសន្ធៅ ... ដោយការចេញទៅសិក្សានៅបរទេសក៏ ត្រូវខកខាន លោកតាទួតដួងសម្បត្តិនិងមិត្តជិតស្និទ្ធតាំងពីកុមារភាពឈ្មោះ ***កែវ រតនៈ*** បានរួមគំនិតរួម ភាគហ៊ុនគ្នាបើកហាងលក់ គ្រឿងឧបភោគបរិភោគតូចមួយនៅភ្នំពេញ ក្នុងពេលដែលពាណិជ្ជករភាគច្រើន ជាពិសេសអ្នករកស៊ីជាជនជាតិបរទេសនៅ កម្ពុជា បានបិទហាងលក់ដូរស្ទើរអស់ វេចបង្វេចដាក់មេផាយចេញពីស្រុកខ្មែរ។ សង្គ្រាមបារាំង ជប៉ុន និងជម្លោះខ្មែរសៀម ក្នុង អំឡុងសង្គ្រាមលោកលើកទីពីរ ពុំបានធ្វើឱ្យហាងរតនៈសម្បត្តិដួលរលំទេ បែរជាធ្វើឱ្យការរកស៊ីកាន់តែរីកលូតលាស់ ព្រោះទោះ ជាច្បាំងគ្នាដល់ណា មនុស្សនៅតែត្រូវការបរិភោគអាហារដោយខានមិនបាន។ ទាំងបារាំង ទាំងជប៉ុន ទាំងខ្មែរចាប់តាំងពីលំដាប់ អភិជនរហូតដល់រាស្ត្រ កំសត់ក្រក្រី បានរាប់អានហាងរតនៈសម្បត្តិជាមិត្ត អ្នកខ្លះគាំទ្រ អ្នកខ្លះអង្វរ សុំកុំឱ្យហាងនេះបិទទ្វារ



ដូចហាងដទៃៗ កំលោះសម្បត្តិនិងកំលោះរតនៈ តែងញញឹមថ្លែងអំណរគុណដល់អតិថិជនគ្រប់រូប ហើយប្រកាសពាក្យសន្យាថាលើកលែងតែហាងត្រូវយន្តហោះទម្លាក់គ្រាប់បែកមកចំ ពុំនោះទេ ទោះជានៅសល់តែអង្ករមួយកំប៉ុង ក៏ហាងរតនៈសម្បត្តិនៅតែបើកទ្វារដែរៗ

ក្រោយសង្គ្រាមលោកបានបញ្ចប់ទៅ ហាងរតនៈសម្បត្តិកាន់តែចម្រើនដុះដាលរហូតដល់ក្លាយជាក្រុមហ៊ុនរតនៈសម្បត្តិ ទទួលលក់ចេញនិងទិញចូលគ្រឿងឧបភោគបរិភោគជាច្រើនប្រភេទ មានជាអាទិ៍អង្ករ ពោត សណ្តែក ត្រីងៀត ត្រីឆ្អើរ ប្រហុក ទឹកត្រីដែលជាផលិតផលក្នុងស្រុក និងផលិតផលនាំចូលមកពីប្រទេសជិតខាងនិងប្រទេស ចិន ជប៉ុន រួមមានម្ហូបដាក់ក្នុងកែវឬកំប៉ុងបន្លែ និងផ្លែឈើស្រស់ គ្រៀមផ្សេងៗដែលអ្នកស្រុកខ្មែរនិយមរាប់អាន និងគ្រឿងភេសជ្ជៈនាំចូលពីអឺរ៉ុបៗ

មុខជំនួញកំពុងតែកាក់កប មិត្តភាពស្រាប់តែប្រេះឆា គឺកំលោះម្ចាស់ក្រុមហ៊ុនទាំងពីរអាត្មាចាប់ចិត្តស្នេហាលើស្ត្រីតែម្នាក់!

ដោយហេតុថាកំលោះរតនៈជាមនុស្សជើងធើតដៃរហ័ស ក៏ឆក់ឱកាសដណ្តើមនាងនោះបានទៅរៀបការបាត់ៗ មិន ត្រឹមតែចេះប្រព្រឹត្តអំពើលួកថ្លើមមិត្តក្នុងរឿងស្នេហាទេ នាយកែវ រតនៈបានប្រើកល ល្បិចលេបត្របាក់យកក្រុមហ៊ុនរតនៈសម្បត្តិជាកម្មសិទ្ធផ្តាច់មុខតែម្នាក់ឯងទៀតៗ





កំលោះដួង សម្បត្តិទ្រាំនឹងក្តីឈឺចាប់នឹងអំពើមិត្តទ្រុស្តមិត្តនេះមិនបានក៏និរទេសខ្លួន រសាត់តែលតោលរហូតដល់ស្រុកប៉ៃលិនៗ ពេលភ្ញាក់ស្មារតី ហែលឆ្លងរួចផុតអំពីសមុទ្រទុក្ខសោក លោកសម្បត្តិបានតាំងចិត្តប្តេជ្ញាកសាងជីវិតថ្មីៗ លោកបានរៀបការនិងចាប់ផ្តើមមុខរបរជំនួញឡើងវិញ ... ខិតខំបណ្តុះបណ្តាលបុត្រាតែមួយ (គឺលោកតា ដួង កែវកុសល ជាជីតារបស់សុកគ្រា) ឱ្យខិតខំហ្វឹកហាត់ខាងផ្នែកជំនួញឱ្យជំនាញ ដើម្បីកសាងកេរ្តិ៍ឈ្មោះគ្រួសារនិងមានឱកាសទៅសើរើក្តីរកយុត្តិធម៌និងទាមទារមកវិញនូវតម្លៃដើមទុននិងកម្លាំងញើសឈាមរបស់លោកសម្បត្តិ ដែលមានចំណែកស្មើភាគហ៊ុនពាក់កណ្តាលនៃក្រុមហ៊ុនរតនៈសម្បត្តិៗ ប៉ុន្តែការព្យាយាមរបស់មនុស្ស មិនដូចការគូសវាសរបស់វាសនា ... មុខជំនួញថ្មី របស់លោកសម្បត្តិបានប្រព្រឹត្តទៅយ៉ាងយឺតៗ ផ្ទុយស្រលះពីក្រុមហ៊ុនរតនៈសម្បត្តិដែលធ្លាប់ល្បីឈ្មោះស្រាប់ ក៏កាន់តែរីកចម្រើនរុងរឿងល្បីល្បាញណាស់ទៅទៀតៗ កាន់តែអកុសល ប្រទេសបានកើតកលយុគរីករវធ្ងន់ធ្ងរ គ្រួសារលោកសម្បត្តិត្រូវរត់គេចចេញពីសង្គ្រាមកាប់សម្លាប់គ្នាក្នុងស្រុកខ្មែរ ហើយភៀសខ្លួនទៅរស់នៅឯប្រទេសអូស្ត្រាលីៗ លោកសម្បត្តិត្រូវស្លាប់នៅស្រុកគេ ទាំងសុបិនមិនបានក្លាយជាការពិតៗ

លោកដួង កែវកុសលចង់សម្រេចបំណងប្រាថ្នារបស់ឪពុកណាស់ ទើបនៅពេលគាត់មានជំនឿច្បាស់ថាស្រុកកំណើតមានសន្តិភាពស្រួលបួលហើយ លោកក៏វិលត្រលប់មកបោះទុនរកស៊ីនៅស្រុកខ្មែរ ទីបំផុតក៏ប្រមូលកូនចៅមករស់នៅកម្ពុជានិងបង្កើតក្រុមហ៊ុនសម្បត្តិពាណិជ្ជឡើងៗ គួរអនិច្ចា ឱកាសសងសឹកទាមទារបំណុល មិនទាន់មកដល់ផង លោកតាកុសលក៏អនិច្ចកម្មទៅបាត់ម្នាក់ទៀតៗ

*ពេលបានអានកំណត់ហេតុជាលើកដំបូង សុភក្រ្តាហូរទឹកភ្នែករហាមដោយក្តីឈឺ ចាប់និងភ្ញើងកំហឹងពេញណែនឱរា។ នាងក៏មានចម្ងល់ខ្លាំងណាស់ដែរ ថាហេតុអ្វីនាងមិនដែលឮលោកតានិយាយរំឭកអំពីប្រវត្តិដ៏កំសត់របស់លោកតាទួតសម្បត្តិ និងពីគំនុំដ៏ជ្រៅចំពោះពួកត្រកូលម្ចាស់ក្រុមហ៊ុនរតនៈសម្បត្តិ ដល់ម្តងណាសោះ? នៅទីបំផុត នាងក៏សន្និដ្ឋានថា ប្រហែលមកពីលោកតាគ្មានទំនុកចិត្តថាអាចសម្រេចបំណងបាន ព្រោះរតនៈសម្បត្តិជាក្រុមហ៊ុនធំ មានកម្លាំងនិងដើមទុនរឹងមាំ បែរមកគ្រួសារនាងវិញ លោកតាមានសុខភាពមិនសូវល្អ ឪពុកនាងក៏ស្លាប់បាត់ បងប្រុសនាងនៅវ័យក្មេងហើយគ្មានចំណូលចិត្តលើមុខរបរជួញដូរនេះទៀត តើ មានសង្ឃឹមអីទៅប្រកួតប្រជែងសងសឹកនឹងគេកើត?*

*ក្រោយពេលបានអានដឹងពីប្រវត្តិដូរចត់ពីកំណត់ហេតុហើយ សុភក្រ្តាមិនអាចនៅស្ងៀមធ្វើមិនដឹងមិនឮទៀតបានឡើយ! ប្រហែលនេះជាប្រស្នាឬបេសកកម្មពិសេស ដែលលោកតាបានទុកឱ្យនាងជាអ្នកដោះស្រាយឬបំពេញបន្ត! ដូច្នេះហើយ ទើបតាំងពីអាយុ១៦ឆ្នាំមក ក្រមុំរូបល្អចិត្តដែកបានប្តេជ្ញាថាត្រូវសម្រេចយុទ្ធនាការសង សឹកនឹងពួកក្រុមគ្រួសារម្ចាស់ក្រុមហ៊ុនរតនៈសម្បត្តិឱ្យបាន ...។*





# បំភ្លេចងាយម្ល៉េះ

ថ្ងៃមត្រូវអូនកាត់ ប្រមាត់ត្រូវអូនក្តិច យកដៃមកជាន់
ពន្ទិចឱ្យលង់ ឈឺហួសលែងនិយាយ
ដូចវាយមួយព្រនង់ លួចសំពោងពីក្រោយខ្នង
ឱ្យស្លាប់។

មិនសមទុកចិត្ត ទ្រុស្តមិត្តក្បត់មិត្តឯង ធ្លាក់យកស្នេហ៍
មិនគិតក្រែងបុណ្យបាប រលាកផ្សាបេះដូង
ដើមទ្រូងត្រូវគេកាប់ គេប្រញាប់ឱ្យផាច់លះបង់ស្នេហ៍។



មិនចង់ដឹងថាស្រស់ព្រលឹងស្នេហ៍គេប៉ុណ្ណា
មិនសួរថាហេតុអ្វីជីវ៉ាព្រមស្នេហ៍រូបគេ
តែចង់ឮចង់ស្តាប់ពាក្យពិត វរមិត្តមានស្នេហ៍បងទេ
ហេតុអ្វីចិត្តប្រែ ប្រែប្រួលបំភ្លេច
មួយរំពេចបំភ្លេចងាយម្ល៉េះ?



ទប់ចិត្តមិនឱ្យស្តាយ
ទប់កាយមិនឱ្យយោគ
ទោះពន្ធកមានកលល្បិចគេចវេះ
ស្ងប់ស្ងៀមបៀមទុក្ខព្រួយរលួយស្ទើររលេះ
ជួបប្រទះទុក្ខសោកព្រោះរឿងស្នេហ៍។

មិនចង់ដឹងថាស្រស់ព្រលឹងស្នេហ៍គេប៉ុណ្ណា មិនសួរថាហេតុអ្វីជីវ៉ាព្រមស្នេហ៍រូបគេ
តែចង់ឮចង់ស្តាប់ពាក្យពិត វរមិត្តមានស្នេហ៍បងទេ
ហេតុអ្វីចិត្តប្រែ ប្រែប្រួលបំភ្លេច មួយរំពេចបំភ្លេចងាយម្ល៉េះ?

រូបភាពដកស្រង់ចេញពី Music Video
"គ្មានខ្លឹមសារ"
របស់ផលិតកម្ម SSB

ពុំដឹងឈ្មោះអ្នកនិពន្ធបទភ្លេងនិងទំនុកច្រៀង
ច្រៀងដោយៈ ព្រាប សុវត្ថិ
ផលិតកម្មៈ រស្មីហង្សមាស